www.kidworship.kr

# អ៊ីសាកនិងរេបិកា

- 8th Story -



51Page

**Abraham** ឥឡូវនេះ អ៊ីសាកមានអាយុល្មមនឹងរៀបការ។ បើដូច្នេះ ខ្ញុំគួរតែរកប្រពន្ធល្អមួយអោយគាត់ហើយពេលនេះ។

**Nar** អ័ប្រាហាំក៏បានសំរេចចិត្តរកប្រពន្ធសំរាប់អ៊ីសាក។ ប៉ុន្តែអាប្រាហាំមិនចង់ឲ្យអ៊ីសាករៀបការជាមួយស្រីជនជាតិកាណាននោះទេ។ អ័ប្រាហាំបានគិតថា នឹងរកស្រីដែលនៅស្រុកខារ៉ានជាស្រុកកំណើតរបស់គាត់ មកអោយធ្វើជាប្រពន្ធអ៊ីសាកវិញ។

ក្រោយមកអ័ប្រាហាំបានហៅអ្នកបំរើ ដែលគាត់ទុកចិត្តបំផុតមកប្រាប់ថា

**Abraham** ចូរអ្នកទៅស្រុកខារ៉ាន ដើម្បីរកប្រពន្ធមួយអោយអ៊ីសាក ជាកូនប្រុសរបស់ខ្ញុំទៅ។

ពេលនោះ ព្រះជាម្ចាស់និងដឹកនាំអ្នកហើយ។

**Nar** ក្រោយមក អ្នកបំរើនោះ បានចេញដំណើរទៅស្រុកខារ៉ានជាមួយសត្វអូដ្ឋ១០ក្បាល សម្រាប់ជាកាដូអោយដល់ប្រពន្ធរបស់អ៊ីសាក។

**Nar** នៅទីបំផុត អ្នកបំរើនោះ បានមកដល់ស្រុកខារ៉ានគឺជិតដល់ម៉ោងអាហារពេលល្ងាចតែម្តង។  ក្នុងពេលនោះ អ្នកបំរើ អស់កំលាំងណាស់ ពីព្រោះធ្វើដំណើរឆ្ងាយពេក។  អ្នកបំរើនោះ ក៏បានអង្គុយសំរាកក្បែរអណ្តូងទឹក ដែលនៅជិតទីក្រុង។  មានស្រីជាច្រើន មកដងទឹកពីអណ្តូងនោះ ដើម្បីរៀបចំធ្វើអាហារពេលល្ងាច។

**Servant** តើខ្ញុំគួរទៅរកប្រពន្ធមួយអោយអ៊ីសាកនៅឯណាបាន?

**Nar** អ្នកបំរើចាស់នោះ ពិបាកចិត្តយ៉ាងខ្លាំង។

ប៉ុន្តែក្រោយមក គាត់បានចាំពាក្យសំដីរបស់អាប្រាហាំថា

**Abraham** ព្រះជាម្ចាស់នឹងដឹកនាំអ្នក។



52Page

**Nar** បន្ទាប់មក អ្នកបរើនោះ ក៏បានលុតជង្គង់នៅជិតអណ្តូង ហើយបានអធិស្ឋានទៅព្រះជាម្ចាស់ថា

**Servant** ព្រះអម្ចាស់! សូមអោយស្រីៗនៅក្នុងទីក្រុងនេះ នឹងមកដងទឹកនៅអណ្តូងនេះ។  ក្នុងចំនោមស្រីៗទាំងនោះ បើមានស្រីណាមួយដែលអោយទឹកមកខ្ញុំនិងសត្វអូដ្ឋរបស់ខ្ញុំ នោះខ្ញុំនឹងដឹងហើយថាស្រីនោះគឺជាប្រពន្ធដែលព្រះអង្គបំរុងទុកដល់អ៊ីសាក។



53Page

**Nar** មិនយូរប៉ុន្មាន មានស្រីម្នាក់ បានយកក្អមមួយដើរសំដៅមកអណ្ដូងទឹក។ ស្រីនោះ ពិតជាគួរអោយស្រលាញ់និងស្លូតត្រង់ណាស់។
ខណៈពេលស្រីនោះ កំពុងដងទឹកពីអណ្ដូង ស្រាប់តែអ្នកបំរើនោះបានឃើញនាង។
បន្ទាប់មក អ្នកបំរើនោះ ដើរទៅជិតនាងហើយនិយាយទៅនាងថា

**Servant** តើឱ្យខ្ញុំសុំទឹកពីក្អមរបស់នាងបន្តិចបានទេ?

**Rebekah** នេះទឹក! សូមញ៉ាំចុះលោកម្ចាស់ ។
ហើយខ្ញុំនឹងដងទឹកអោយអូដ្ឋរបស់លោកម្ចាស់ដែរ។

**Nar** អ្នកបម្រើនោះ មានការភ្ញាក់ផ្អើលពេលឮសំដីនេះ។

**Servant** ព្រះជាម្ចាស់ បានឮពាក្យខ្ញុំអធិស្ឋានដល់ទ្រង់ហើយទ្រង់បានឆ្លើយតបមកខ្ញុំ។ ដូច្នេះ ស្រីនេះ ពិតជាប្រពន្ធរបស់អ៊ីសាក ដែលជាម្ចាស់ខ្ញុំហើយ។

**Nar** បន្ទាប់មក អ្នកបំរើនោះ មានចិត្តត្រេកអរណាស់ ព្រោះរកឃើញស្រីដែលក្លាយជាប្រពន្ធរបស់អ៊ីសាក។

---



54Page

**Nar** ស្រីនោះឈ្មោះថា រេបិកា។
អ្នកបំរើនោះ បានអោយចិញ្ចៀនមួយនិងខ្សែដៃពីរទុកជាការជូនទៅដល់រេបិកា។ ក្រោយមក អ្នកបំរើនោះ ក៏បានទៅជួបឪពុករបស់រេបិកា។ ឪពុកម្ដាយរេបិកា បានទទួលស្វាគមន៍ដល់អ្នកបំរើនោះ។
អ្នកបំរើនោះ បានប្រាប់ឪពុករេបិកា អំពីដើមហេតុ ដែលគាត់មកដល់ទីនេះថា

**Servant** ខ្ញុំជាអ្នកបំរើរបស់លោកអ័ប្រាហាំ។ លោកអ័ប្រាហាំម្ចាស់ខ្ញុំ មានកូនប្រុសម្នាក់ឈ្មោះអ៊ីសាក។ ខ្ញុំមកទីនេះ គឺដើម្បីរកប្រពន្ធអោយដែលត្រូវជាកូនប្រុសលោកអ័ប្រាហាំម្ចាស់របស់ខ្ញុំ។

**Father** នេះជាផែនការណ៍របស់ព្រះជាម្ចាស់។ នេះរេបិកា។
ចូរអ្នកនាំនាង ហើយអោយនាងធ្វើជាប្រពន្ធរបស់កូនប្រុសម្ចាស់របស់អ្នកចុះ។

**Nar** ពេលនោះ អ្នកបំរើ បានទទួលការយល់ព្រមពីឪពុករបស់រេបិកាអោយរៀបការ។ រេបិកាក៏និយាយដែរថានាងសុខចិត្តទៅជាមួយគ្នា។

---



55Page

**Nar** ស្អែកឡើង ពេលព្រឹកព្រលឹម អ្នកបំរើនោះនិងរេបិកា បានចាប់ផ្ដើមធ្វើដំណើរទៅផ្ទះរបស់អ័ប្រាហាំ។
ឯអ៊ីសាក កំពុងតែដើរបណ្ដើរគិតបណ្ដើរអំពីព្រះជាម្ចាស់។
ពេលនោះ អ៊ីសាក់បានឃើញអ្នកទាំង២ ហើយបានគិតក្នុងចិត្តថា



56Page

**Isaac** តើស្រីនោះជានរណា?

**Nar** បន្ទាប់មក អ៊ីសាកបានដើរចូលទៅជិតអ្នកបំរើនោះ។
អ្នកបំរើនោះ បានប្រាប់អ៊ីសាករឿងទាំងអស់ ដែលបានកើតឡើង។
ក្រោយមក អ៊ីសាកក៏បាននាំរេបិកាចូលក្នុងផ្ទះរបស់គាត់ បន្ទាប់មក
អ៊ីសាកនិងរេបិកាបានរៀបការជាមួយគ្នា ហើយពួកគេបានទទួល
ពរជាច្រើនមកពីព្រះជាម្ចាស់។
បន្ទាប់មក អ៊ីសាកនិងរេបិកា បានស្រលាញ់គ្នាទៅវិញទៅមក
និងបានរស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយទៅ។